002/19-09-2007-ECCC/TC
E1/323

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 08 / 2015
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ៣០៤

រៀបចំដោយ៖ សែ កុលវុឌ្ឍី និង **Matthew McCARTHY**

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម Martin KAROPKIN, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង លាង, លោក Dale LYSAK, លោក Travis FARR, លោក Joseph Andrew BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក ហុង គឹមសួន, លោក វ៉ែន ពៅ, លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវ៉ន, លោកស្រី ទី ស្រ៊ីនណា |
| សាក្សី/ដើមបណ្តឹង៖ លោក សែន សុផុន (2-TCCP-220) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក Russell HOPKINS, លោក ឡុង ង៉េត, កញ្ញា ស្រី ណាក់, លោក វ៉ាត សុម៉ៅ, លោក លី សុតុល្យ, កញ្ញា Joëlle TRAMPERT, លោក Richard LATTA |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៥.៥៣ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.០៦ | បញ្ចប់ម៉ោង៖ ១១.០៤ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.០៥ | បញ្ចប់ម៉ោង៖ ១៣.១០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤១ | បញ្ចប់ម៉ោង៖ ១៤.៥៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៣ ម៉ោង និង ៣៤ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៦ | ០៩.០៨ |
| ការធ្វើសារណាផ្ទាល់មាត់ទាក់ទងទៅនឹងការដាក់ឯកសារដែលបានមកពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២ | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br><br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៩<br>០៩.១២<br>០៩.៥៧<br>០៩.៣២<br>០៩.៣៦<br>០៩.៤៧ | ០៩.១២<br>០៩.៣២<br>១០.០៤<br>០៩.៣៦<br>០៩.៤៧<br>០៩.៥៧ |

| | | | |
|---|---|---|---|
| សេចក្តីសម្រេចលើការពន្យារពេលក្នុងការចេញសេចក្តីសម្រេចលើបញ្ហានៃការដាក់បង្ហាញឯកសារ និងការផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ពេលរសៀល | អង្គជំនុំជម្រះ | ១១.០៤ | ១១.០៥ |
| សេចក្តីសម្រេចលើការកែសម្រួលកាលបរិច្ឆេទសវនាការទាក់ទងនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម | អង្គជំនុំជម្រះ | ១៣.១០ | ១៣.១៥ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន (2-TCCP-220) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា | ១៣.១៧<br>១៣.២០<br>១៤.១៦ | ១៣.២០<br>១៤.១៦<br>១៥.៥០ |
| ការកត់សម្គាល់របស់មេធាវី នួន ជា ទាក់ទងនឹងរបៀបនៃការតាំងសំណួររបស់សហព្រះរាជអាជ្ញា ដោយយោងទៅលើសេចក្តីសម្រេចរបស់តុលាការកំពូល F26 | មេធាវីការពារក្តី នួន ជា<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១៤.២១<br>១៤.២៥<br>១៤.៣៤ | ១៤.២៥<br>១៤.២៨<br>១៤.៣៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការធ្វើសារណាផ្ទាល់មាត់ទាក់ទងទៅនឹងការដាក់ឯកសារដែលបានមកពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២</u>**

តាមការណែនាំរបស់អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា មេធាវីនាំមុខ មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានធ្វើសារណាផ្ទាល់មាត់ទៅលើបញ្ហា ថាតើការដាក់បង្ហាញឯកសារពីក្នុងសំណុំ

រឿង០០៤ ទៅក្នុងសំណុំរឿង០០២/០២ អនុញ្ញាតឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីឱ្យភាគីអាច ពិនិត្យមើលទៅលើឯកសារទាំងនោះដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងបានពន្យារពេលក្នុង ការចេញសេចក្តីសម្រេចរបស់ខ្លួន និងបានលើកសវនាការទៅធ្វើនៅពេលរសៀលចាប់ពីម៉ោង ១.០០។

**<u>សេចក្តីសម្រេចលើការកែសម្រួលកាលបរិច្ឆេទនៃការធ្វើសវនាការលើអង្គហេតុទំនប់ត្រពាំងថ្ម</u>**

នៅពេលចាប់ផ្តើមសវនាការនៅពេលរសៀល អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្អាកការធ្វើសវនាការ លើអង្គហេតុទំនប់ត្រពាំងថ្ម រយៈពេល ១ សប្តាហ៍ ដើម្បីអនុញ្ញាតឱ្យភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការ ពិនិត្យមើលទៅលើឯកសារដែលបានដាក់បង្ហាញថ្មីៗនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយពិចារណាទៅ លើការធ្វើដំណើរមក អ.វ.ត.ក ក្នុងរយៈចម្ងាយផ្លូវដ៏ឆ្ងាយនោះ អង្គជំនុំជម្រះសម្រេចស្តាប់សក្ខីកម្មដើម បណ្តឹងរដ្ឋប្បវេណី 2-TCCP-220 និងសាក្សី 2-TCW-258 ទៅតាមកាលបរិច្ឆេទដែលបានកំណត់រួចហើយ នោះ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះបានសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-866 ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយបន្ទាប់មកស្តាប់សក្ខីកម្ម សាក្សីដែលមានរហស្សនាម 2-TCW-926 ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ ១ មករា ដោយសារតែ សក្ខីកម្មរបស់សាក្សីទាំងពីររូបនេះនឹងមិនប៉ះពាល់ដល់ការដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះថ្មីៗ នេះទេ។

**<u>ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន (2-TCCP-220)</u>**

អង្គជំនុំជម្រះ បានតាំងសំណួរបឋមទៅដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន (2-TCCP-220) បន្ទាប់មក មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបានតាំងសំណួរបន្តទៅកាន់ដើមបណ្តឹង រដ្ឋប្បវេណី។

**<u>ការជំទាស់របស់មេធាវីការពារក្តី នួន ជា ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការកំពូល F26</u>**

មេធាវីការពារក្តី នួន ជា បានជំទាស់នៅក្នុងអំឡុងពេលនៃការតាំងសំណួររបស់សហព្រះរាជអាជ្ញា ទៅកាន់ ដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការកំពូលចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៥។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសេចក្តីជំទាស់នេះ ហើយបានសម្រេចឱ្យភាគីចៀសវាង ក្នុងការសួរសំណួរដដែលៗទៅលើចម្លើយពីមុនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការបញ្ជាក់ពីចម្លើយ របស់គាត់នោះទេ ប៉ុន្តែអាចអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរំលឹកការចងចាំ ឬដើម្បីបង្ហាញ ពីភាពជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4821 | D22/1232 | 00523260-00523269; 00916889-00916892; 00909831-00909836 | Civil Party application of SEN Sophon 09-VU-00979 | P | 00523262 00523263 00523264 | 00916889 00916890 | 00909832 00909833 00909834 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319/25.2 | | N/A; 01120381-01120389; N/A | Annex I: Disclosure of Case 004 Documents Related to Case 002 Pursuant to Case 004-D193/28 | SC | N/A | | N/A |
| E319/25.3 | | N/A; 01120390-01120400; N/A | Annex I: Disclosure of Case 004 Documents Related to Case 002 Pursuant to Case 004-D193/28 | SC | N/A | | N/A |
| E319/25.3.2 | D5/1077 | 01022761-01022771; 01073583-01073592; N/A | Civil Party Application of [REDACTED] | SC | | | N/A |
| F26 | | 01108641-01108646; 01108636-01108640; 01110266-01110270 | Supreme Court Chamber Directions on the conduct of the Hearing | P | 01108645 01108646 | 01108639 | 01110269 |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៨)
- សេចក្ដីសម្រេចលើការកែសម្រួលកាលបរិច្ឆេទនៃការធ្វើសវនាការលើអង្គហេតុទំនប់ត្រពាំងថ្ម

ដើម្បីអនុញ្ញាតឱ្យភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យមើលទៅលើឯកសារដែលបានដាក់បង្ហាញថ្មីៗនេះ និងសេចក្តីសម្រេចក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-220 និងសាក្សី 2-TCW-258 តាមកាលបរិច្ឆេទដែលបានកំណត់រួចហើយ។ (១៣.១៥)

- សេចក្តីសម្រេចផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការកំពូល F26 ដែលណែនាំឱ្យភាគីក្នុងការចៀសវាងការអានកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានធ្វើពីមុនយកមកប្រើប្រាស់ក្នុងគោលបំណងធ្វើការបញ្ជាក់ទៅលើចម្លើយរបស់សាក្សី។ (១៤.៣៦)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផនទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥។ (១៥.៥២)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលទុន្សី Matthew McCARTHY